សារជូនចំពោះមនុស្សទូទាំងផែនដី

# សាសនាមិនពិត ជិតត្រូវបំផ្លាញហើយ!

- តើសាសនាមិនពិតជាអ្វី?
- តើសាសនាមិនពិតនឹងត្រូវបំផ្លាញយ៉ាងដូចម្ដេច?
- តើនេះតម្រូវឱ្យលោកអ្នកធ្វើអ្វីខ្លះ?

**តើសាសនាមិនពិតជាអ្វី?** តើលោកអ្នកពិបាកចិត្តទេ ពេលដែលឃើញឬឮអំពីមនុស្សប្រព្រឹត្តអំពើអាក្រក់ដោយអាងសាសនា? តើលោកអ្នកទាស់ចិត្តទេ នៅពេលមនុស្សដែលអះអាងថាខ្លួនបម្រើព្រះ បែរជាធ្វើសង្គ្រាម ភេរវកម្ម និងអំពើពុករលួយ? តើហេតុអ្វីបានជាសាសនាមើលទៅដូចជាដើមហេតុនៃបញ្ហាច្រើនដល់ម្ល៉េះ?

ដើមហេតុនៃបញ្ហាទាំងនេះមិនមែនជាសាសនាទាំងអស់ទេ តែគឺជាសាសនា***មិនពិត***វិញ។ ព្រះយេស៊ូគ្រិស្ទ អ្នកបង្ហាត់បង្រៀនសាសនាមួយរូបដែលត្រូវគេគោរពទូទាំងផែនដីធ្លាប់បញ្ជាក់ថា សាសនាមិនពិតនាំឱ្យមនុស្សប្រព្រឹត្តអាក្រក់ ដូចជា «ដើមអាក្រក់ ក៏តែងមានផ្លែអាក្រក់ដែរ»។ (ម៉ាថាយ ៧:១៥-១៧) តើសាសនាមិនពិតបង្កើតឱ្យមានផលអ្វី?



## សាសនាមិនពិត

■ **សាសនាមិនពិតចូលប្រឡូកក្នុងសង្គ្រាមនិងរឿងនយោបាយ:** ទស្សនាវដ្ដីមួយសរសេរថា៖ «ទូទាំងទ្វីបអាស៊ីនិងប្រទេសផ្សេងទៀតដែរ ពួកមេដឹកនាំអាត្មានិយមដែលស្រេកឃ្លានអំណាចកំពុងតែយកជំនឿសាសនារបស់ប្រជាជនមកធ្វើជាឈ្នាន់ ដើម្បីបំពេញគោលដៅរបស់ខ្លួនដោយឥតអៀនខ្មាស»។ ជាលទ្ធផលទស្សនាវដ្ដីនោះព្រមានថា៖ «ពិភពលោកទាំងមូលកំពុងតែរកកល់ឆ្កួត»។ (*Asiaweek*) អ្នកដឹកនាំសាសនាមួយរូបដ៏ល្បីឈ្មោះនៅសហរដ្ឋអាម៉េរិកធ្លាប់មានប្រសាសន៍ថា៖ «យើងត្រូវសម្លាប់ពួកភេរវជនចោល ទើបលែងមានការសម្លាប់គ្នា»។ អ្នកដឹកនាំសាសនានោះបានស្នើឱ្យ«សម្លាប់ពួកគេចោលទៅ ដោយអាងនាមព្រះជាម្ចាស់»។ នេះផ្ទុយពីព្រះគម្ពីរ ពីព្រោះព្រះគម្ពីរបានសរសេរថា៖ «បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក»។ (យ៉ូហានទី១ ៤:២០) ព្រះយេស៊ូថែមទាំងមានបន្ទូលថា៖ *«ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ»*។ (ម៉ាថាយ ៥:៤៤) យ៉ាងណាក៏ដោយ តើមានសាសនាប៉ុន្មានដែលមានសមាជិកចូលប្រឡូកក្នុងសង្គ្រាម?

■ **សាសនាមិនពិតក៏បង្រៀនអ្វីដែលមិនពិតដែរ:** សាសនាភាគច្រើនបង្រៀនថា ព្រលឹងឬវិញ្ញាណជាអ្វីមួយដែលយើងមើលមិនឃើញនៅក្នុងរូបកាយមនុស្ស ហើយពេលដែលមនុស្សស្លាប់ទៅព្រលឹងឬវិញ្ញាណនោះរស់បន្តទៅទៀត។ តាមរយៈសេចក្ដីបង្រៀននេះ សាសនាជាច្រើនជញ្ជក់យកផលប្រយោជន៍ពីសមាជិក ដោយគិតថ្លៃលើការអធិស្ឋានដើម្បីជួយវិញ្ញាណក្ខន្ធមនុស្សស្លាប់។ ក៏ប៉ុន្តែ ក្នុងព្រះគម្ពីរមានសេចក្ដីបង្រៀនផ្សេង។ ព្រះគម្ពីរសរសេរថា៖ *«ព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់»*។ (អេសេគាល ១៨:៤) «មនុស្សដែលរស់ គេដឹងថាខ្លួននឹងស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹងអ្វីឡើយ»។ (សាស្ដា ៩:៥) ព្រះយេស៊ូបានបង្រៀនថា មនុស្សស្លាប់នឹងត្រូវប្រោសឱ្យរស់ឡើងវិញ។ ប៉ុន្តែបើមនុស្សមានព្រលឹងអមតៈពិតមែន នោះការប្រោសឱ្យពួកគេរស់ឡើងវិញគ្មានប្រយោជន៍ទាល់តែសោះ។ (យ៉ូហាន ១១:១១-២៥) តើសាសនារបស់លោកអ្នកបង្រៀនថាព្រលឹងមិនចេះស្លាប់ទេ?

■ **សាសនាមិនពិតបណ្ដោយឱ្យប្រព្រឹត្តអំពើអសីលធម៌ខាងកាម:** នៅប្រទេសជាច្រើន សាសនាផ្សេងៗតែងតាំងបព្វជិតដែលជាមនុស្សស្រឡាញ់ភេទដូចគ្នា ហើយក៏ជំរុញឱ្យរដ្ឋាភិបាលទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍ រវាងមនុស្សភេទដូចគ្នាទៀតផង។ សូម្បីតែសាសនាខ្លះៗដែលបង្រៀនថាអំពើអសីលធម៌ខាងកាមគឺខុស ក៏នៅតែត្រាប្រណីដល់អ្នកដឹកនាំសាសនាដែលរួមភេទជាមួយកូនក្មេង។ ក៏ប៉ុន្តែតើព្រះគម្ពីរបង្រៀនយ៉ាងណាអំពីអំពើអសីលធម៌ខាងកាម? ព្រះគម្ពីរសរសេរត្រង់ៗថា៖ *«កុំឱ្យច្រឡំឡើយ! ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ [«ពួកអ្នករួមសង្វាសនឹងភេទដូចគ្នា»]*

. . . *មិនដែលបានគ្រងនគរព្រះទុកជា[មត៌ក]ឡើយ*»។ (កូរិនថូសទី១ ៦:៩, ១០; *ខ.ស.*) តើអ្នកធ្លាប់ដឹងអំពីសាសនាផ្សេងៗ ដែលបណ្ដោយឱ្យមនុស្សប្រព្រឹត្តអំពើអសីលធម៌ខាងកាមឬទេ?

តើអ្វីនឹងកើតឡើងដល់សាសនាដែលបង្កើតផលអាក្រក់បែបនេះ? ព្រះយេស៊ូបានព្រមានថា៖ «អស់ទាំងដើមឈើណា ដែលមិនកើតផលផ្លែល្អ នោះត្រូវតែកាប់បោះចោលទៅក្នុងភ្លើង»។ (ម៉ាថាយ ៧:១៩) ដូច្នេះសាសនាមិនពិតនឹងត្រូវបំផ្លាញចោលជាក់ជាពុំខាន! ក៏ប៉ុន្តែ តើសាសនាមិនពិតនឹងត្រូវបំផ្លាញចោលយ៉ាងដូចម្ដេច និងនៅពេលណា? បទទំនាយមួយក្នុងព្រះគម្ពីរនៅសៀវភៅវិវរណៈ ជំពូកទី១៧និងទី១៨មានចម្លើយចំពោះសំណួរទាំងនោះ។

**សាសនាមិនពិត បញ្ចេញឥទ្ធិពល «លើស្ដេចទាំង ប៉ុន្មាននៅផែនដី»**

## តើសាសនាមិនពិតនឹងត្រូវបំផ្លាញចោលយ៉ាងដូចម្ដេច?



ចូរគិតអំពីនិមិត្តរូបដូចតទៅនេះ ដែលត្រូវរៀបរាប់ក្នុងព្រះគម្ពីរ: មានស្រីសំផឹងមួយរូបអង្គុយពីលើសត្វចម្លែកមួយដែលគួរឱ្យខ្លាច។ សត្វនោះមានក្បាល៧និងស្នែង១០។ (វិវរណៈ ១៧:១-៤) តើស្រីសំផឹងនេះតំណាងអ្វីទៅ? ព្រះគម្ពីរសរសេរថា ស្រីនេះបញ្ចេញឥទ្ធិពល«លើស្ដេចទាំងប៉ុន្មាននៅផែនដី» ហើយក៏ស្លៀកពាក់ពណ៌ស្វាយ ប្រើកំញាន ថែមទាំងមានទ្រព្យសម្បត្តិសម្បូរហូរហៀរ។ ម្យ៉ាងទៀត «*អស់ទាំងសាសន៍*បានវង្វេង» ដោយសារមន្តអាគមរបស់ស្រីនោះ។ (វិវរណៈ ១៧:១៨; ១៨:១២, ១៣, ២៣, កំណែជាអក្សរទ្រេត) ព្រះគម្ពីរជួយឱ្យយល់ថា ស្រីសំផឹងនេះជានិមិត្តរូបសាសនាទូទាំងពិភពលោក។ ស្រីនោះមិនមែនតំណាងសាសនាតែមួយទេ តែតំណាងសាសនាទាំងអស់ដែលបង្កើតផលអាក្រក់។

សត្វចម្លែកដែលស្រីសំផឹងនោះជិះ ជានិមិត្តរូបរដ្ឋាភិបាលទាំងឡាយរបស់មនុស្ស។* (វិវរណៈ ១៧:១០-១៣) ស្រីសំផឹងឬសាសនាមិនពិត ជិះសត្វចម្លែកនោះឬបណ្ដារដ្ឋាភិបាល ក្នុងន័យថាសាសនាមិនពិតខំបញ្ចេញឥទ្ធិពលទៅលើការសម្រេចចិត្តនិងគោលដៅរបស់បណ្ដារដ្ឋាភិបាល។

ក៏ប៉ុន្តែមិនយូរទៀត នឹងមានព្រឹត្តិការណ៍ដ៏អស្ចារ្យមួយកើតឡើង។ «ស្នែងទាំង ១០ ដែលអ្នកឃើញ ព្រមទាំងសត្វនោះផង នោះនឹងស្អប់ដល់ស្រីសំផឹង ហើយនឹងបំផ្លាញវាទៅ ទាំងធ្វើឱ្យវានៅអាក្រាត រួចនឹងស៊ីសាច់វា ហើយដុតវានៅក្នុងភ្លើង»។ (វិវរណៈ ១៧:១៦) រដ្ឋាភិបាលទាំងឡាយរបស់មនុស្សនឹងធ្វើអ្វីដ៏គួរឱ្យរន្ធត់ណាស់ គឺនឹងវាយប្រហារទៅលើសាសនាមិនពិតហើយបំផ្លាញចោលទាំងស្រុង! នេះនឹងកើតឡើងយ៉ាងលឿនមួយរំពេច។ តើអ្វីនឹងបណ្ដាលឱ្យរដ្ឋាភិបាលធ្វើដូច្នេះ? ក្នុងព្រះគម្ពីរនៅសៀវភៅវិវរណៈឆ្លើយថា៖ «*ព្រះទ្រង់*បានបណ្ដាលចិត្តគេ ឱ្យធ្វើតាមគំនិត*ទ្រង់*»។ (វិវរណៈ ១៧:១៧, កំណែជាអក្សរទ្រេត) ដូច្នេះគឺព្រះទេ ដែលកាត់ទោសដល់សាសនាមិនពិត ដោយសារអំពើគួរឱ្យស្អប់ខ្ពើមជាច្រើនដែលវាបានធ្វើដោយអាងព្រះនាមទ្រង់។ សមស្របតាមយុត្តិធម៌គ្រប់លក្ខណ៍ ទ្រង់នឹងប្រើបណ្ដារដ្ឋាភិបាលដែលជាគូកនរបស់វាជាមធ្យោបាយបំផ្លាញសាសនាមិនពិតចោល។

តើលោកអ្នកត្រូវធ្វើយ៉ាងណា ប្រសិនបើមិនចង់ទទួលសេចក្ដីហិនវិនាសជាមួយនឹងសាសនាមិនពិត? ព្រះមានបន្ទូលដាស់តឿនយើងថា៖ ‹រាស្ត្រយើងអើយ! ចូរចេញពីទីនោះមក›។ (វិវរណៈ ១៨:៤) ឥឡូវនេះហើយ ជាពេលដែលត្រូវចេញពីសាសនាមិនពិត! ប៉ុន្តែតើត្រូវចេញពីសាសនាមិនពិតរួចទៅឯណាវិញ? មិនមែនត្រូវទៅជាអ្នកដែលអត់ជឿព្រះសោះ ដ្បិតមនុស្សបែបនោះក៏គ្មានអនាគតដែរ។ (ថែស្សាឡូនីចទី២ ១:៦-៩) គឺមានតែចូលជ្រកកោនក្នុងសាសនាពិតវិញ។ តើលោកអ្នកអាចសម្គាល់សាសនាពិតបានយ៉ាងដូចម្ដេច?

**‹រាស្ត្រយើងអើយ! ចូរចេញពីទីនោះមក›**

* ដើម្បីទទួលព័ត៌មានថែមទៀតអំពីការពន្យល់នេះ សូមមើលសៀវភៅស្ដើង*ចូរចាំយាមចុះ!* ទំព័រ១២-១៣ បោះពុម្ពដោយស្មរបន្ទាល់ព្រះយេហូវ៉ា។



# របៀបសម្គាល់សាសនាពិត

តើសាសនាពិតគួរបង្កើតផលល្អអ្វីខ្លះ?—ម៉ាថាយ ៧:១៧

## សាសនាពិត

■ **សាសនាពិតប្រកបទៅដោយសេចក្ដីស្រឡាញ់:** សមាជិកនៃសាសនាពិត«មិនមែនជារបស់ផងលោកីយ» ក៏មិនបែកបាក់គ្នាដោយសារសាសន៍ឬវប្បធម៌ ហើយពួកគេ‹ស្រឡាញ់គ្នាទៅវិញទៅមក›។ (យ៉ូហាន ១៣:៣៥; ១៧:១៦; កិច្ចការ ១០:៣៤, ៣៥) ជាជាងសម្លាប់គ្នា ពួកគេសុខចិត្តប្ដូរជីវិតជំនួសអ្នកជឿគ្នីគ្នា។ —យ៉ូហានទី១ ៣:១៦

■ **សាសនាពិតទុកចិត្តព្រះបន្ទូលរបស់ព្រះ:** ជាជាងបង្រៀន«ទំនៀមទំលាប់»និង«បញ្ញត្តរបស់មនុស្ស» សាសនាពិតបង្រៀនដោយយកព្រះបន្ទូលរបស់ព្រះក្នុងព្រះគម្ពីរជាមូលដ្ឋានវិញ។ (ម៉ាថាយ ១៥:៦-៩) តើហេតុអ្វី? ដោយសារ«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឱ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់»។—ធីម៉ូថេទី២ ៣:១៦

■ **សាសនាពិតជួយពង្រឹងសាមគ្គីភាពក្នុងក្រុមគ្រួសារ ហើយក៏បណ្ដាលឱ្យមានខ្នាតតម្រាសីលធម៌ខ្ពង់ខ្ពស់:** សាសនាពិតបង្រៀនប្ដីទាំងឡាយឱ្យ‹ស្រឡាញ់ប្រពន្ធ ដូចជាស្រឡាញ់រូបកាយរបស់ខ្លួនដែរ› ក៏បង្រៀនប្រពន្ធទាំងឡាយឱ្យ«កោតខ្លាចប្ដី» ហើយថែមទាំងបង្រៀនកូនឱ្យ«ស្ដាប់បង្គាប់មាតាបិតាខ្លួន»។ (អេភេសូរ ៥:២៨, ៣៣; ៦:១) ម្យ៉ាងទៀត អ្នកដែលមានមុខតំណែងទទួលខុសត្រូវក្នុងសាសនាពិត ត្រូវជាជនគំរូខាងសីលធម៌។—ធីម៉ូថេទី១ ៣:១-១០

តើមានសាសនាណាមួយដែលមានលក្ខណៈទាំងអស់នេះឬទេ? សៀវភៅមួយដែលបោះពុម្ពនៅឆ្នាំ២០០១សរសេរថា៖ «ប្រសិនបើមនុស្សច្រើនជាងប្រព្រឹត្តតាមអ្វីដែលស្មរបន្ទាល់ព្រះយេហូវ៉ាបង្រៀននិងប្រព្រឹត្តនោះ រឿងខ្លោចផ្សាហៅថាហូឡូខស [ការប្រល័យពូជសាសន៍ នៅប្រទេសអាឡឺម៉ង់]ពុំបានកើតឡើងទេ ហើយក៏លែងមានការប្រល័យពូជសាសន៍យ៉ាយីពិភពលោកតទៅទៀតឡើយ»។—*Holocaust Politics*



**នៅ២៣៥ប្រទេស ស្មរបន្ទាល់ព្រះយេហូវ៉ាមិនត្រឹមតែបង្រៀនអំពីខ្នាតតម្រាសីលធម៌ក្នុងព្រះគម្ពីរប៉ុណ្ណោះទេ តែពួកគេក៏ប្រព្រឹត្តតាមទៀតផង។ យើងសូមលើកទឹកចិត្តលោកអ្នកឱ្យសុំស្មរបន្ទាល់ព្រះយេហូវ៉ាជួយបង្រៀនអ្វីដែលព្រះតម្រូវ ដើម្បីអាចថ្វាយបង្គំទ្រង់តាមរបៀបទ្រង់សព្វព្រះហឫទ័យ។ ឥឡូវនេះជាពេលដែលត្រូវចាត់វិធានការ។ កុំបង្អែបង្អង់ឡើយ។ សាសនាមិនពិតជិតត្រូវបំផ្លាញហើយ!—សេផានា ២:២, ៣**